**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមករា ឆ្នាំ២០២២

នៅក្នុងខែមករា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅះ

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន១លើក។

ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យឯកអគ្គរាជទូតកម្ពុជាតែងតាំងថ្មីចំនួន៣រូប ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ណែនាំ មុនពេលចេញដំណើរបំពេញបេសកកម្មនៅប្រទេសជប៉ុន សហរដ្ឋអាមេរិក ម៉ិកស៊ិក និងប្រទេសហ្វីលីពីន នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យលោក **អាស្សាអាត អាល់ហ្សាវ៉ារី** ប្រតិភូតំណាងអង្គការបណ្តុះបណ្តាលវប្បធម៌ឥស្លាមកូវ៉ែត ដែលជាប្រភពម្ចាស់ជំនួយរបស់សមាគមប្រភពល្អកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យឯកឧត្តម **BUI THANH SON** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

គ-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី កងកម្លាំង និងអាជ្ញាធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ និងសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសក **គង់ ខាត់** ក្នុងឱកាសបុណ្យខួបគម្រប់៤ឆ្នាំ និងជូនដល់ដួងវិញ្ញាណក្ខន្ធ មាតាបិតា ញាតិកាទាំង៧សន្តាន ដែលបានបែកកាយរំលាយខន្ធទៅកាន់លោកខាងមុខ នៅវត្តសុវណ្ណគីរី (ហៅវត្តជើងផ្នុក) ស្ថិតនៅក្នុងភូមិជើងផ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធមហាឧបាសក ពុទ្ធសាសនូបត្ថម្ភក៍ **ជឹង គីង** ត្រូវជាបិតាក្មេកឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកការងារអតីតយុទ្ធជន និងជនពិការ ជាអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងចូលរួមរំលែកទុក្ខជាមួយមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ **ចេង សំផាន** ព្រមទាំងក្រុមគ្រួសារ ស្ថិតនៅក្រុងតាខ្មៅ ខេត្តកណ្តាល

-បានអញ្ជើញទស្សនាទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមិទ្ធផលថ្មី ជាប្រវត្តិសាស្ត្រ ដែលឆ្លុះបញ្ចាំងពីស្នាដៃស្ថាបត្យកម្ម និងរចនាប័ទ្មជាតិ ព្រមទាំងបានលើកកម្ពស់វប្បធម៌ និងអត្តសញ្ញាណជាតិគួរជាទីមោទនភាព

-បានអញ្ជើញសួរសុខទុក្ខឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភា(ក្រុម៣) ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ស្ថិតនៅក្នុងសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៤) នៅវិមានព្រឹទ្ធសភា។

ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៥ច្បាប់។

## ១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុំ កា** អនុប្រធានទី១ ព្រឹទ្ធសភា

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុល-

សេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៤) នៅវិមានព្រឹទ្ធសភា។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣០ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរាជបណ្ឌិត្យសភាកម្ពុជា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ**

-បានអនុញ្ញាតឱ្យឯកឧត្តម **សុខ ឥសាន្ត** ប្រធានគណៈកម្មការទី៤ ព្រឹទ្ធសភា ចូលជួបពិភាក្សាការងារចាំបាច់មួយចំនួន។

**គ-សកម្មភាពចុះមូលដ្ឋាន**

-បានអនុញ្ញាតឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅឃុំអញ្ចាញរូង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។

**ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៤) នៅវិមានព្រឹទ្ធសភា។

ង-ការពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៥ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងគណៈកម្មការជំនាញព្រឹទ្ធសភា សុំពិនិត្យ និងសម្រេចលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្ដីព្រាងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីសហគ្រាសពាណិជ្ជកម្ម

២- សេចក្ដីព្រាងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

៣- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋកូរ៉េ

៤- ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ:០៩៤/១២២១/លគ.គក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

៥- ពិនិត្យ និងសម្រេចលើរបាយការណ៍ ស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ នីតិកាលទី៤។

## ៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំពេញអង្គចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើរបៀបវារៈ ដូចខាងក្រោម៖

១- ស្ដាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ ព្រឹទ្ធសភានីតិកាលទី៤

២- ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤ ជំនួសលោកជំទាវ **ឱ សុខុម** ដែលបានទទួលមរណភាព

៣- ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា នីតិកាលទី៤

៤- ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម

៥- ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

៦- ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-បានអញ្ជើញចូលរួមកិច្ចប្រជុំបើកទូលាយជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន៣ រួមមាន ៖ ១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម ២-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ៣-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ-កម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ។

### ៤.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីវឌ្ឍនភាព និងឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

-បានអញ្ជើញចូលរួមក្នុងពិធីជួបសវនាការការងារជាមួយឯកឧត្តម **ប៉ែន កុសល្យ** អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ ដើម្បីឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស និងការអនុវត្តច្បាប់ តាមដាន និងជំរុញការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ សិទ្ធិដីធ្លី និងសិទ្ធិទទួលបានសុខភាព ជាពិសេសស្ត្រី និងកុមារ ក្នុងកំឡុងពេលមានវិបត្តិ

កូវីដ-១៩ ព្រមទាំងស្តាប់ការបំភ្លឺអំពីការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ចំនួន ៦៥៩គ្រួសារ ទាក់ទងនឹងករណីដីធ្លី នៅសង្កាត់សំរោង ក្រុងសំរោង និងឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។

## ៤.៣ មុខងារតំណាង

-បានអនុញ្ញាតឱ្យក្រុមការងារ របស់សកលវិទ្យាល័យភូមិន្ទភ្នំពេញ ដឹកនាំដោយ ឯកឧត្តម **ជេត ជាលី** សាកលវិទ្យាធិការនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-បានអញ្ជើញចូលរួមពិធីសំណេះសំណាលរវាងក្រុមសមាជិកាព្រឹទ្ធសភា ជាមួយសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ស្តីពី " វឌ្ឍនភាព និងឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ " ក្រោមអធិបតីភាពលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទី៦ ទី៧ និងទី៨ ដើម្បីពិនិត្យពិភាក្សាលើកម្មវិធីត្រៀមចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ និងអាជ្ញាធរក្រុងសួង ស្តីពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន, បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១, របាយការណ៍ទូទាត់ថវិកាចំណូល-ចំណាយ និងពិនិត្យឆ្លងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២២

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរាជបណ្ឌិត្យសភាកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាប្រមូលធាតុចូល ដើម្បីជំរុញវិស័យកសិកម្ម កសិឧស្សាហកម្ម ដាំ ចិញ្ចឹម និងកែច្នៃ ជួយដល់កសិករខ្នាតតូច មធ្យម និងខ្នាតធំ ដើម្បីបំពេញតម្រូវការទីផ្សារក្នុងប្រទេស និងនាំចេញ កិច្ចប្រជុំដំណើរការដោយមានការចូល

រួមមតិយោបល់ពីសមាជិកព្រឹទ្ធសភា សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា អ្នកចិញ្ចឹមជ្រូក អ្នកចិញ្ចឹមគោ អ្នកចិញ្ចឹមមាន់ សមាគមវារីវប្បករកម្ពុជា សមាគមវិស័យដាំដុះ សមាគមក្រុមការងារកសិឧស្សាហកម្មដំណាំដូងប្រេង និងកៅស៊ូ និងមតិចូលរួមយោបល់ពីសមាគមក្រុមការងារស្រូវអង្ករ នៅសាលសិក្ខាសាលាបណ្ណាល័យ វិមានព្រឹទ្ធសភា

-បានទទួលពាក្យបណ្ដឹងចំនួន១០ករណី និងកំពុងពិនិត្យសិក្សាចំនួន១៤ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន៣ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន៣ករណី

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការសកម្មភាពឆ្នាំ២០២២ របស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CWPD) នៅខេត្តកំពង់ធំ

-បានអញ្ជើញជាអធិបតីក្នុងវគ្គបណ្ដុះបណ្ដាលបំប៉នសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំរាជធានី ខេត្ត តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៤) នៅសាលសិក្ខាសាលាខាងត្បូងវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន៤១លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេស អប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ ព្រមទាំងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ចំនួន៩៩លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកោះកុង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

### ៤.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ

ប្រតិភូក្រុមប្រឹក្សាភិបាលសាលាអន្តរជាតិប៉ារ៉ាហ្គោន (Paragon International School) ដឹកនាំដោយលោក Damir Musaev នាយកប្រតិបត្តិនៃកម្មវិធីសាលា ចូលជួបសម្តែងការគួរសម

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយលោកស្រី **TEO Lay Cheng** ឯកអគ្គរដ្ឋទូតប្រទេសសិង្ហបុរី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងក្រុមអ្នកវិនិយោគទុនមកពីប្រទេសជប៉ុនចំនួន៣រូប ដែលចង់បោះទុនវិនិយោគសាងសង់ភូមិឋានបែបបុរាណជប៉ុននៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍ កសិទេសចរណ៍ម៉ុង ឫទ្ធីសែនជ័យ។

ថ្ងៃពុធ ១កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

*កិត្តិសង្គហបណ្ឌិត* **ទេព ងន**

<u>*ចម្លងជូន*</u>

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ខ្ទួលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*